# ការលែងលះ និង នីតិវិធីនៃការលែងលះ

ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១៨

Japan Federal Bar Associations

មេធាវី YOSHISAWA TOSHIYUKI

# I ដំណើរការនៅពេលទទួលរឿងក្ដីលែងលះ និង ចំណុចត្រូវប្រុងប្រយ័ត្ន

１． ការត្រៀមមុនពេលផ្ដល់ប្រឹក្សាផ្ទាល់

ដើម្បីក្ដាប់បានច្បាស់លាស់នូវទំនាក់ទំនងអង្គហេតុ និង ឆន្ទៈរបស់អ្នកទទួលប្រឹក្សា យើងត្រូវឲ្យអ្នកមកប្រឹក្សារៀបចំជាមុនដូចខាងក្រោម៖

❶ គំនូសបង្ហាញទំនាក់ទំនងគ្រួសារ（សរសេរដូចជា អាយុ និង ការងារ រស់នៅជាមួយគ្នា ឬ រស់នៅបែកគ្នា ជាដើម） ※សៀវភៅគ្រួសារ ជាអាទិ៍

❷ តារាងពេលវេលាធម្មតាៗ（ដំណើររឿងរហូតដល់ពេលលែងលះ→អង្គហេតុសម្រាលកូន ជាអាទិ៍→ដំណើររឿងដែលនាំឲ្យមានជម្លោះរវាងប្ដីប្រពន្ធ ជាអាទិ៍）

❸ ឯកសារផ្សេងៗដែលអាចដឹងអំពីដំណើររឿងមុននឹងឈានដល់ការពិភាក្សានេះ ដូចជា សំបុត្រ និង អ៊ីម៉ែល រូបថត និង ការថតសម្លេងជាដើម ※អាចជាភស្ដុតាងនៅពេលលែងលះដោយការព្រមព្រៀង និង លែងលះដោយតុលាការ

❹ ក្រៅពីនេះ គម្រោងអំពីហេតុផលនៃការទាមទារឲ្យលែងលះ និងលក្ខខណ្ឌនៃការលែងលះដែលចង់បានជាដើម។

## 2. ចំណុចត្រូវចងចាំប្រយ័ត្នជាទូទៅនៅពេលប្រឹក្សាជាមួយអ្នកមកប្រឹក្សា

❶ សាកសួរទំនាក់ទំនងអង្គហេតុ ដោយផ្តោតលើចំណុចដូចជា មាន ឬ គ្មានមូលហេតុនៃការលែងលះ（ទំនាក់ទំនងអង្គហេតុដែលត្រូវនឹងក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ក～ង）កត្តាដែលត្រូវពិចារណាលើការបែងចែកទ្រព្យសម្បត្តិ（ក្រមរដ្ឋប្បវេណី (ហៅថា «CC»)មាត្រា៩៨0 កថាខណ្ឌទី២ ចំណុច ខ និង កថាខណ្ឌទី៣）អំណាចមេបា（ CC ចាប់ពីមាត្រា ១0៣៧）ជាដើម។

❷ ពិចារណាលើស្មេរភាពនៃអារម្មណ៍របស់អ្នកមកប្រឹក្សា។

មានករណីខ្លះអ្នកមកប្រឹក្សាអាចមានអារម្មណ៍តានតឹងខ្លាំង ហេតុនេះ យើងត្រូវព្យាយាមបង្កើតការជឿទុកចិត្តជាមួយអ្នកមកប្រឹក្សា ហើយសាកសួព័តមាន។

❸ ពិចារណាលើរឿងឯកជនរបស់អ្នកមកប្រឹក្សា។

## ៣. សាកសួរអំពីលក្ខខណ្ឌ និង គោលបំណងក្នុងករណីលែងលះ

សាកសួរជាមុនអំពី ស្ថានភាពនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធម្នាក់ៗ ចំណូលទាំងសងខាង ស្ថានភាពនៃការចំណាយលើសោហ៊ុយអាពាហ៍ពិពាហ៍ និងស្ថានភាពកូន ជាអាទិ៍។

លើសពីនេះ យើងត្រូវសាកសួរអំពីការបែងចែកទ្រព្យសម្បត្តិ និង សំណងជម្ងឺចិត្តជាអាទិ៍ដែលអ្នកមកប្រឹក្សាចង់បាន អំណាចមេបាលើកូន (=សិទ្ធិបីបាច់រក្សាលើរាងកាយ + សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ) សិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងក្នុងករណីដែលគ្មានបំណងរស់នៅជាមួយកូន និងគោលបំណងទាមទារសោហ៊ុយចិញ្ចឹមបីបាច់កូន (សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន) ក្នុងករណីរស់នៅជាមួយកូន ជាអាទិ៍។

## II ឧទាហរណ៍ជាក់ស្តែង អង្គហេតុជាមុន

1. ខ្លឹមសារសំខាន់នៃសម្ដីរបស់ស្ត្រី B ដែលជាកូនក្ដី

ប្ដី A (អាយុ ៣៥ឆ្នាំ) ធ្វើការជាមន្ត្រីរាជការរយៈពេល ១៥ឆ្នាំហើយ។ ប្រពន្ធ B គ្មានការងារ បានរៀបការកាលពី ១២ឆ្នាំមុន និង រស់នៅភ្នំពេញតាំងពីដើមមក។ ពួកគេទាំង ២ មានកូនស្រី C អាយុ ១0 កំពុងរៀននៅសាលាបឋម។

A មានទំលាប់ចាយវាយខ្ជះខ្ជាយខ្លាំង ហើយចូលចិត្តផឹកស្រា នៅពេលថ្មីៗនេះ គាត់ញៀននឹងជាតិអាកុល ហើយរាល់ថ្ងៃត្រឡប់មកផ្ទះស្រវឹងជោគជាំ។ លើសពីនេះ ចាប់ពីប្រហែល ១ឆ្នាំមុន ពេលផឹកស្រានៅផ្ទះ គាត់បានប្រើអំពើហិង្សាលើ B។ ទាំង C ក៏មានការភ័យខ្លាចនឹងទង្វើរបស់ A ដែរ ។ B មិនអាចទ្រាំបាន ក៏បាននាំ C ត្រឡប់ទៅផ្ទះនៅទីក្រុងភ្នំពេញកាលពី ៣ខែមុន។ ម៉្យាងទៀត ឪពុកម្តាយរបស់ B មិនសូវធូធារ ហើយមិនអាចទ្រទ្រង់ជីវភាពរបស់ B និង C បានទេ។ នៅក្នុងអំឡុងពេលរួមជីវភាពអាពាហ៍ពិពាហ៍ជាមួយ A B បានខំប្រឹងចាត់ចែងការចំណាយក្នុងផ្ទះ និង មើលថែកូន C ដើម្បីឲ្យប្តី A អាចផ្តោតតែលើការងារបាន។

## 2. ចំណុចដែលសាកសួរពី B និង គោលបំណងរបស់ B

❶ ចង់លែងលះជាមួយ A។

❷ គាត់មិនដែលនិយាយអំពីការលែងលះជាមួយ A ទេ។

→យើងមិនច្បាស់អំពីគំនិតរបស់ A។

❸ ទ្រព្យរួមរបស់ A និង B ព្រមទាំងស្ថានភាពចំណូលរបស់ម្នាក់ៗ ជាអាទិ៍

A ជាមន្ត្រីរាជការ មានប្រាក់ខែចំនួន ៣លាន រៀល។ ពួកគេមានប្រាក់សន្សំក្នុងគណនីចំនួន ៨០ លានរៀល ដែលជាទ្រព្យទទួលបានពីប្រាក់ខែក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នៅធនាគារ X។ ប៉ុន្តែ ផ្ទះដែលរស់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាផ្ទះជួល។

B គ្មានទ្រព្យដោយឡែកដូចជា ប្រាក់សន្សំក្នុងគណនី ឬ អចលនវត្ថុអ្វីនោះទេ ក្រៅពីរបស់ប្រើប្រាស់ប្រចាំថ្ងៃបន្តិចបន្តួច។

❹ B បានរួមចំណែកកាត់បន្ថយការចំណាយក្នុងផ្ទះ និងថែរក្សាទ្រព្យរួម ហើយយើងមិនច្បាស់ថានៅពេលអនាគត គាត់អាចធ្វើការបាននោះទេ (សូមយោងក្រមរដ្ឋប្បវេណីមាត្រា៩៨0 កថាខណ្ឌទី២ ចំណុចខ និង ការថាខណ្ឌទី៣)។

❺ ចង់បានអំណាចមេបាចំពោះ C (សិទ្ធិបីបាច់រក្សាលើរាងកាយ + សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ)។

❻ C ក៏ចង់រស់នៅជាមួយម្តាយ B ដែរ។

❼ ចង់ទទួលបានការបង់សោហ៊ុយចិញ្ចឹមបីបាច់កូន C ពី A។

❽ គាត់បានទទួលរងការឈឺចាប់ដោយសារការលែងលះ ហេតុនេះ គាត់ចង់ទាមទារសំណងជម្ងឺចិត្តចំពោះ A ដែលធ្វើឲ្យមានមូលហេតុនៃការលែងលះ។

## 3. ការចចារជាមួយភាគីម្ខាងទៀត A

1. ជូនដំណឹងទៅ A អំពីការទទួលបានអាណត្តិពី B និងក្លាយជាអ្នកតំណាងឲ្យB ព្រមទាំងការចចារទាក់ទងនឹងការលែងលះ ក្នុងនាមជាមេធាវីតំណាងឲ្យ B។

2. ចំណុចត្រូវចចារ

❶ បញ្ជាក់ឆន្ទៈរបស់ A អំពីការលែងលះ

* ករណីយល់ព្រមលែងលះ → ដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។
* ករណីមិនយល់ព្រមលែងលះ → ដាក់ពាក្យបណ្ដឹងលែងលះដោយតុលាការ។

❷ ចចារអំពីការបែងចែកទ្រព្យសម្បត្តិ (ករណីដែល A យល់ព្រមលែងលះ)

＊ក្រៅពីទ្រព្យរួម ៥0% យើងត្រូវចចារដោយពិចារណាលើ「ស្ថានភាពផ្សេងៗ」 ដូចជា ទំហំនៃការបរិច្ចាគដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួម អំឡុងពេលអាពាហ៍ពិពាហ៍ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។

❸ ចចារអំពីសិទ្ធិអំណាចមេបាចំពោះ C និង សោហ៊ុយចិញ្ចឹមបីបាច់កូន ព្រមទាំងការបង់ប្រាក់សំណងជម្ងឺចិត្ត

(ករណីដែល A យល់ព្រមលែងលះ)

## Ⅲ ការដាក់ពាក្យសុំលែងលះ (លែងលះដោយការព្រមព្រៀង)

※ករណីដែល A យល់ព្រមលែងលះ

**【យោង】បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងទាក់ទងនឹងការលែងលះដោយការព្រមព្រៀង** (ហៅថា «NSCC»)

❶ CC មាត្រា៩៧៩ ការលែងលះដោយការព្រមព្រៀង

NSCC មាត្រា៣ កថាខណ្ឌទី១ តារាងឧបសម្ព័ន្ធ (ហៅថា «ឧប.») ផ្នែកទី៤ ចំណុចទី៥ ការលែងលះដោយការព្រមព្រៀង

❷ CC មាត្រា៩៧១ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ដោយយោងតាមបញ្ញត្តិនៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

❸ CC មាត្រា៩៨០ ការបែងចែកទ្រព្យសម្បត្តិ

NSCCមាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៦ ការបែងចែកទ្រព្យសម្បត្តិ

❹ CC មាត្រា១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

❺ CC មាត្រា១០៤០ សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី១៣ ការសម្រេចសេចក្ដីអំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទង និងចំណែកបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

❻ CC មាត្រា១០៤១ សិទ្ធិទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូន

NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី១៤ សិទ្ធិទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូន

## 1. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ជាអាទិ៍

(NSCC មាត្រា២៦ កថាខណ្ឌទី២~៤)

① ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និង ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

② ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និង

អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ

※ 「អង្គហេតុដែលជាមូលហេតុនៃការទាមទារ」 គឺជាការអះអាងអង្គហេតុដែលជាមូលហេតុគាំទ្រដល់ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ។

※ ក្រៅពីនេះ ត្រូវដាក់ឯកសារភស្តុតាង (មាត្រា២៦ កថាខណ្ឌទី៤)។

## 2. ពាក្យសុំលែងលះដោយការព្រមព្រៀង

(ក្រមរដ្ឋប្បវេណីមាត្រា៩៧៩ NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៥)

1. ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
   ទាមទារដីកាសម្រេច
   បង្គាប់ឲ្យអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត
2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ
   *អង្គហេតុដែលជាអត្ថិភាពនៃការព្រមព្រៀងអំពីការលែងលះរវាង A និង B។

## 3. ពាក្យសុំបែកចែកទ្រព្យសម្បត្តិ ※ករណីដែលប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបាន ជាអាទិ៍

(CC មាត្រា៩៨០ NSCC មាត្រា៣ កថាខណ្ឌទី១ ឧប. ផ្នែកទី៤ ចំណុចទី៦)

1. ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

ទាមទារដីកាសម្រេច បង្គាប់ឲ្យភាគីម្ខាងទៀតបង់ប្រាក់ចំនួន ៥០លាន រៀល ដែលជាទ្រព្យរួមទៅឲ្យអ្នកដាក់ពាក្យសុំ។

2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

＊ការបរិច្ចាគរបស់ B ដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួមមានទំហំធំ។

＊អំឡុងពេលអាពាហ៍ពិពាហ៍មានរយៈពេលវែងដល់ ១២ឆ្នាំ។

＊B គ្មានការងារ ហើយមានភាពលំបាកក្នុងការរកការងារ ក្រោយពេលលែងលះ។

＊មូលហេតុនៃការលែងលះបណ្តាលមកពីការប្រើហិង្សារបស់ A ចំពោះ B ជាអាទិ៍(ចំណែកដែលជាសំណងជម្ងឺចិត្ត)។

※សរសេរអំពី កម្រិតបរិច្ចាគរបស់ B សម្រាប់ធ្វើលទ្ធកម្ម ថែរក្សា និង បង្កើនទ្រព្យរួម រយៈពេលអាពាហ៍ពិពាហ៍  និង កម្រិតជីវិភាពក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ អាយុ និង លទ្ធភាពធ្វើការក្រោយពេលលែងលះជាដើម ក្រៅពីនេះ ខ្លឹមសារ និង ទំហំនៃការងារផ្ទះរបស់ B (CC មាត្រា៩៨០ កថាខណ្ឌទី៣) ព្រមទាំងព័ត៌មានទាំងអស់ដែលអាចជាប្រយោជន៍សម្រាប់ B។

## 4. ពាក្យសុំទាមទារចំណែកបន្ទុកចំណាយលើការគ្រប់គ្រងថែរក្សាកូន

※ករណីដែលប្ដីប្រពន្ធមិនអាចពិភាក្សាគ្នាបាន ជាអាទិ៍

（CC មាត្រា១០៤០ កថាខណ្ឌទី១ NSCCមាត្រា៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី១៣）

1． ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

ទាមទារដីកាសម្រេច បង្គាប់ឲ្យភាគីម្ខាងទៀតបង់ប្រាក់ចំនួន ១លាន រៀល រៀងរាល់ថ្ងៃចុងខែ ដែលជាថ្លៃចិញ្ចឹមបីបាច់កូន ចាប់ពីថ្ងៃទីXX ខែXX ឆ្នាំ២០XX ដល់ថ្ងៃទីXX ខែXX ឆ្នាំ២០XX។

2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

＊A ធ្វើជាមន្ត្រីរាជការ និងមានប្រាក់ខែ ៣លាន រៀល។

＊B គ្មានការងារ និង គ្មានប្រាក់ចំណូល ហើយមានភាពលំបាកក្នុងការរកការងារនាពេលអនាគត ហើយឪពុកម្ដាយរបស់ B ដែល B ត្រូវចាប់ផ្ដើមរស់នៅជាមួយក៏មានជីវភាពលំបាក ។

※សរសេរអំពីលទ្ធភាពធ្វើការរបស់ B ក្រោយពេលដែល B លែងលះ ក្រៅពីចំណូលរបស់ A ។

## IV ការដាក់ពាក្យបណ្តឹងលែងលះ (ការលែងលះដោយតុលាការ)
※ ករណីដែល A មិនព្រមលែងលះ

【យោង】 បញ្ញត្តិនៃ CC និង ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាក់ទងនឹងការលែងលះដោយតុលាការ (ហៅថា «PSL»)

❶ CC មាត្រា ៩៧៨ មូលហេតុនៃការលែងលះ

PSL មាត្រា៣ ចំណុច គ (វិសាលភាពនៃច្បាប់នេះ)

បណ្តឹងលែងលះតាមបញ្ញត្តិនៃ「មូលហេតុនៃការលែងលះ」ក្នុងក្រមរដ្ឋប្បវេណីមាត្រា៩៧៨

❷ CC មាត្រា ៩៨០ ការបែងចែកទ្រព្យសម្បត្តិ

PSL មាត្រា២២ កថាខណ្ឌទី១ សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

❸ CC មាត្រា១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះ

PSL មាត្រា២២ កថាខណ្ឌទី១ ការកំណត់អ្នកមានអំណាចមេបា

❹ CC មាត្រា១០៤០ ការចូលជួប និង ប្រាស្រ័យទាក់ទង និង ចំណែកបន្ទុកនៃសោហ៊ុយនៃការគ្រប់គ្រងថែរក្សាកូន

PSL មាត្រា២២ កថាខណ្ឌទី១  ការចាត់ចែងអំពីការគ្រប់គ្រងថែរក្សាកូន

（កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងកូន និង ចំណែកបន្ទុកចំណាយសម្រាប់ការគ្រប់គ្រងថែរក្សាកូន ជាអាទិ៍ ）

❺ PSL មាត្រា២២ កថាខណ្ឌទី២ ការប្រគល់កូន ឬ ការបង់ប្រាក់ ឬ ការផ្តល់តាវកាលិកផ្សេងទៀត

❻ PSL មាត្រា២២ កថាខណ្ឌទី៤

ចំពោះការចាត់ចែងអំពីការកំណត់អំណាចមេបា និង ការគ្រប់គ្រងថែរក្សាកូន ត្រូវយកយោបល់របស់កូនមកពិចារណា

❼ PSL មាត្រា២៣

ត្រូវពិន័យជាប្រាក់ចំនួនមិនលើសពី ១លាន រៀល ក្នុងករណីធ្វេសប្រហែសមិនអនុវត្តដីកាសម្រេចឲ្យអនុវត្ត ការបង្គាប់ឲ្យអនុវត្ត ឬ ការបង្គាប់ឲ្យបង់ប្រាក់

❽ PSL មាត្រា១១　ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការរួមបញ្ចូលការទាមទារសំណងជម្ងឺចិត្តជាមួយនឹងការលែងលះ

# 1. ពាក្យបណ្តឹង

1. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

(ក្រមនីតិវិធីរដ្ឋប្បវេណី (ហៅថា «CCP») មាត្រា៧៥ កថាខណ្ឌទី២ និង ទី៣)

① ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

② ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទាឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

③ សរសេរឲ្យបានច្បាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង អង្គហេតុពាក់ព័ន្ធ

④ សរសេរអំពីភស្តុតាង

2. ការដាក់ភស្តុតាង

※អង្គហេតុដែលទ្រទ្រង់ដល់មូលហេតុនៃការទាមទារ (លិខិត និង រូបថត ជាអាទិ៍)

# ការសរសេរខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ

ទាមទារសាលក្រម

1． បង្គាប់ឲ្យលែងលះដើមចោទ និង ចុងចម្លើយ។

2． កំណត់ឲ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើ C ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ។

3． បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១លាន រៀល រៀងរាល់ថ្ងៃចុងខែ ចាប់ពីថ្ងៃទីXX ខែXX ឆ្នាំ២0XX ដល់ថ្ងៃទីXX ខែXX ឆ្នាំ២0XX ទៅឲ្យដើមចោទ។※1

4． បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥0លាន រៀល ទៅឲ្យដើមចោទ។※2

5． ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

※1　ថ្លៃចិញ្ចឹមបីបាច់

※2　ប្រាក់បែងចែកទ្រព្យ សំណងជម្ងឺចិត្ត

# ការសរសេរអង្គហេតុដែលជាមូលហេតុនៃការទាមទារ

1．ការអះអាងអង្គហេតុដែលជាមូលហេតុនៃការលែងលះ

បង្ហាញអំពីភាពត្រូវគ្នានឹងមូលហេតុណាមួយក្នុងចំណុចទាំងអស់នៃ CC មាត្រា៩៧៨ កថាខណ្ឌទី១ ជាមួយនឹងការអះអាងអំពីទំនាក់ទំនងអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌនៃចំណុចទាំងអស់នោះ (ដាក់ទាំងភស្តុតាងដែលគាំទ្រអង្គហេតុដែលបានអះអាង)។

※ ករណី CC មាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង (ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន)

① អង្គហេតុជាក់ស្តែង A ដែលជាមូលដ្ឋានគាំទ្រចំណុចដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន

② អង្គហេតុជាក់ស្តែង B ...

③ អង្គហេតុជាក់ស្តែង C ...

(ការអះអាងអង្គហេតុដែលជាមូលហេតុនៃការលែងលះ) នៅក្នុងករណីសិក្សានេះ យើងសរសេរនូវចំណុចខាងក្រោម

* អង្គហេតុដែល A ចាយវាយខ្ជះខ្ជាយ និង ញៀនជាតិអាកុល។
* អង្គហេតុដែល A ប្រើអំពើហិង្សាលើ B ជាអាទិ៍ (លក្ខណៈ និង ភាពញឹកញាប់នៃអំពើហិង្សានោះ ស្ថានភាពនៃកន្លែងដែលមានរបួស ជាអាទិ៍)។
* អង្គហេតុស្នាក់នៅផ្សេងគ្នាដោយមូលហេតុនៃអំពើហិង្សារបស់ A។
* ផ្អែកតាមស្ថានភាពខាងលើ ធ្វើឲ្យ B គ្មានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនឹង A។

## 2. ការចាត់ចែងបន្ទាប់បន្សំ (សោហ៊ុយចិញ្ចឹមជីវិត ប្រាក់នៃការបែងចែកទ្រព្យសម្បត្តិ) និង សំណងជម្ងឺចិត្ត

ការអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ

ចំពោះ「អង្គហេតុដែលជាមូលហេតុនៃការទាមទារ」ត្រូវសរសេរអង្គហេតុដែលជាខ្លឹមសារមូលដ្ឋាននៃ「ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ」។

❶ ការទាមទារស្តីពីការបែងចែកទ្រព្យសម្បត្តិ (CC មាត្រា៩៨០ LPS មាត្រា២២ កថាខណ្ឌទី១)

- ＊ការបរិច្ចាគរបស់ B ដើម្បីលទ្ធកម្ម និង ថែរក្សាទ្រព្យរួមមានទំហំធំ។
- ＊អំឡុងពេលអាពាហ៍ពិពាហ៍មានរយៈពេលវែងដល់ ១២ឆ្នាំ។
- ＊B គ្មានការងារ ហើយមានភាពលំបាកក្នុងការរកការងារ ក្រោយពេលលែងលះ។

❷ ការទាមទារអំពីការកំណត់អ្នកមានសិទ្ធិអំណាចមេបា (CC មាត្រា១០៣៧ LPS មាត្រា២២ កថាខណ្ឌទី១)

∗ មិនត្រឹមតែ B នោះទេ C ក៏ចង់រស់នៅជាមួយ B ដែរ (សូមយោង LPS មាត្រា២២ កថាខណ្ឌទី៤)។

∗ C កំពុងតែភ័យខ្លាចចំពោះការស្រវឹងកាចរបស់ A និង អំពើហិង្សាលើ B

∗ B ចិញ្ចឹមបីបាច់ និង ថែទាំ C ស្ទើរទាំងស្រុង ហើយស្ថានភាពថែទាំក៏គ្មានបញ្ហាអ្វីទាំងអស់។

∗ ការស្រវឹងកាច និង ការចាយវាយខ្ជះខ្ជាយ ជាអាទិ៍ ធ្វើឲ្យ A មិនសាកសមជាអ្នកមានអំណាចមេបា។

∗ C មានអាយុ ១០ឆ្នាំ និងជាអាយុអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន។

❸ ការទាមទារសោហ៊ុយចិញ្ចឹមបីបាច់ (CC មាត្រា១0៤0 LPS មាត្រា ២២ កថាខណ្ឌទី១)

＊A ធ្វើជាមន្រ្តីរាជការ និងមានប្រាក់ខែ ៣លាន រៀល។

＊B គ្មានការងារ និង គ្មានប្រាក់ចំណូល ហើយមានភាពលំបាកក្នុងការរកការងារនាពេលអនាគត ហើយឪពុកម្តាយរបស់ B ដែល B ត្រូវចាប់ផ្តើមរស់នៅជាមួយក៏គ្មានជីវភាពធូធារដែរ។

※សរសេរអំពីលទ្ធភាពធ្វើការរបស់ B ក្រោយពេលដែល B លែងលះ ក្រៅពីចំណូលរបស់ A ។

❹ ការទាមទារសំណងជម្ងឺចិត្តដោយសារការលែងលះ (CC មាត្រា៧៥៤ LPS មាត្រា១១)

※ សរសេរអំពី ជីវភាពអាពាហ៍ពិពាហ៍រហូតដល់ទៅ ១២ឆ្នាំ ត្រូវបញ្ចប់ដោយសកម្មភាពដែលត្រូវនឹងមូលហេតុនៃការលែងលះរបស់ A និង អង្គហេតុនានាដែលធ្វើឲ្យមានការខូចខាតសតិអារម្មណ៍។

## 3. ចំណុចដែលត្រូវសរសេរក្នុងឯកសារចម្លើយ

ប៉ុន្តែ ឯកសារចម្លើយដែលដាក់ដោយអ្នកតំណាងចុងចម្លើយដែលបដិសេធការលែងលះ អាចសរសេរដូចខាងក្រោម និង ផ្តល់នូវភស្តុតាងដែលជាមូលហេតុនៃការអះអាងរបស់ចុងចម្លើយ។

### ទី 1. ការឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ

1. ច្រានចោលការទាមទាររបស់ដើមចោទ។
2. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

### ទី 2. បដិសេធចំពោះអង្គហេតុដែលដើមចោទអះអាង

### ទី 3. ការអះអាងរបស់ចុងចម្លើយ

※ ករណី CC មាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង (ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន)

① អង្គហេតុជាក់ស្តែង A ដែលបដិសេធចំណុចដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែងបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន

② អង្គហេតុជាក់ស្តែងB ...

③ អង្គហេតុជាក់ស្តែងC ...

## —អំពីសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង—

CC មាត្រា១០៤០ NSCC មាត្រា ៣ កថាខណ្ឌទី១ ឧប.ផ្នែកទី៤ ចំណុចទី១៣ LPS មាត្រា២២ កថាខណ្ឌទី១

សិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង គឺជាសិទ្ធិទាមទារ ចូលជួប តេទូរស័ព្ទ និង ឆ្លើយឆ្លងសបុត្រជាមួយកូនរបស់ឪពុកម្ដាយដែលមិនចិញ្ចឹមបីបាច់កូន (ឪពុកម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា) ចំពោះឪពុកម្ដាយដែលចិញ្ចឹមបីបាច់កូន។

CC មាត្រា១០៤០ បញ្ញត្តអំពីសញ្ញាណនៃសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទង ចំពោះឪពុកម្ដាយដែលមិនរស់នៅជាមួយកូនដូចខាងក្រោម។

* ឪពុកម្ដាយដែលមានបំណងលែងលះត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន (កថាខណ្ឌទី២)។
* បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ (កថាខណ្ឌទី៤)។
* តុលាការត្រូវកំណត់អំពីការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព (កថាខណ្ឌទី៦)។

## V ដីកាបង្គាប់ឲ្យអនុវត្ត និង ការអនុវត្តដោយបង្ខំ

### 1. ដីកាបង្គាប់ឲ្យអនុវត្ត (LPS មាត្រា២៣)

តុលាការអាចចេញដីកាបង្គាប់ឲ្យបង់ប្រាក់ ជាអាទិ៍ ដោយកំណត់អំឡុងពេលចំពោះបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចធ្វេសប្រហែសក្នុងការបង់ប្រាក់ និង ប្រគល់ទ្រព្យសម្បត្តិដែលបានទទួលស្គាល់តាម LPS មាត្រា២២ ទាក់ទងនឹងការចាត់ចែង (សោហ៊ុយចិញ្ចឹមបីបាច់ ជាអាទិ៍) អំពីការបែងចែកទ្រព្យសម្បត្តិ និង ការគ្រប់គ្រងថែទាំកូន។ ប្រសិនបើមិនធ្វើតាមបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចបង្គាប់ឲ្យពិន័យជាប្រាក់មិនលើសពី ១លានរៀល ហើយតាមរយៈនេះអាចបណ្តាលឲ្យបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចបង់ប្រាក់បាន។

## 2. ការអនុវត្តដោយបង្ខំ (CCP)

ក្រៅពីសាលក្រមតាម LPS ដីកាសម្រេចដែលចូលជាស្ថាពរតាម NSCC ទាក់ទងនឹងការបង់ប្រាក់ និង ការប្រគល់វត្ថុជា អាទិ៍ ក៏ត្រូវក្លាយជាលិខិតអនុវត្តដែលបញ្ញត្តក្នុង CCP មាត្រា៣៥០ និងទទួលបានអានុភាពអនុវត្ត (NSCC មាត្រា៣៨) ដែរ។ ក្នុងករណីបុគ្គលដែលត្រូវបានបង្គាប់ឲ្យអនុវត្តករណីយកិច្ចធ្វេសប្រហែសក្នុងការបង់ប្រាក់ ជាអាទិ៍ យើងអាចដោះស្រាយតាមរយៈការអនុវត្តដោយបង្ខំ (CCP គន្លឹះទី៦) បាន។

## VI សេចក្ដីសន្និដ្ឋាន

នៅប្រទេសជប៉ុនក៏ដោយ ក៏ចំនួននៃម្ដាយ (ឪពុក) ដែលចិញ្ចឹមកូនតែម្នាក់ឯង ក្រោយពេលលែងលះមានបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច និង ជួបបញ្ហាលំបាកផ្នែកជីវភាពប្រចាំថ្ងៃ ព្រមទាំងមានការនឿយហត់ខ្លាំងក្នុងការចញ្ចឹមកូន មានកាន់តែច្រើនឡើងផងដែរ។ ហើយបញ្ហារបស់ឪពុកម្ដាយបណ្ដាលឲ្យកូនទៅពាក់ព័ន្ធជាមួយ និង ត្រូវឃ្លាតឆ្ងាយពីឪពុកម្ដាយណាម្ខាង ជាអាទិ៍ អាចធ្វើឲ្យមានរបួសផ្លូវចិត្តរបស់កូន នឹងប៉ះពាល់ដល់ការរីកលូតលាស់របស់កូន។ នៅពេលចូលរួមក្នុងរឿងក្ដីលែងលះ ក្នុងនាមជាមេធាវី ខ្ញុំយល់ថាត្រូវតែដោះស្រាយដោយប្រុងប្រយ័ត្ន ដោយមើលទៅលើការទ្រទ្រង់ជីវភាពរបស់ភាគី និង សុខមាលភាពរបស់កូនក្រោយពេលលែងលះ។